**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បញ្ជីបណ្ណាល័យព័ត៌មាននិងឯកសារកសិកម្ម**
មកដល់, ថ្ងៃទី..........ខែ..........ឆ្នាំ..........
លេខ....................
ម៉ោង....................

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៥៩៦ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំប្រកាសផ្សព្វផ្សាយរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦

កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង១៥និង០០នាទី រសៀល នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានរៀបចំពិធីប្រកាសសេចក្តីសម្រេចស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីភាពរបស់ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បន្ទាប់ពីបានធ្វើការផ្សព្វផ្សាយនូវសេចក្តីសម្រេចលេខ២៧២ សសរ កសក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចមក ឯកឧត្តមរដ្ឋមន្ត្រីបានធ្វើការណែនាំអំពីការអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

- បានធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ ដែលជាថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការ ថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចក្នុងរយៈពេលកន្លងទៅនេះ និងស្នើឲ្យមានការខិតខំបន្ថែមទៀត ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពក្នុងការបំពេញការងារ
- ត្រូវប្រកាន់យកនូវអត្តចរិកសុភាពរាបសារ តែម៉ឺងម៉ាត់ក្នុងការដឹកនាំបំពេញភារកិច្ចជូនរាជរដ្ឋាភិបាល ដោយអនុវត្តតាមពាក្យស្លោក ងូតទឹក ដុសក្អែល ឆ្លុះកញ្ចក់ ដោយគោរពតួនាទី ឋានានុក្រម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពនីមួយៗ ឲ្យមានភាពរលូន និងប្រសិទ្ធភាពខ្ពស់
- ត្រូវរៀបចំ និងសង្ខេបរបាយការណ៍រាល់ការប្រជុំជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អង្គភាពនីមួយៗ ត្រូវពិនិត្យ និងរៀបចំធ្វើផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ឲ្យមានលក្ខណៈសង្គតិភាពទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ដោយក្នុងនោះថ្នាក់ដឹកនាំក្រសួង អគ្គនាយកកសិកម្ម រដ្ឋបាលព្រៃឈើ អគ្គនាយកកៅស៊ូ រដ្ឋបាលជលផល ត្រូវមានភាពឈ្លាសវៃក្នុងការដឹកនាំ ហើយត្រូវខិតខំប្រឹងប្រែងរកការងារជូនដល់មន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន ជៀសវាងនូវការស្ពឹកស្រពន់។ ទន្ទឹមនឹងនេះ ក៏ត្រូវពិនិត្យមើលអំពីភារកិច្ចដែលអនុវត្តបន្តទៅតាមលំដាប់អាទិភាព ឧទាហរណ៍ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រតាមអនុវិស័យ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ទាំងអស់ដែលត្រូវធ្វើតាមការចាំបាច់។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ករណីបំពេញបេសកកម្មនៅក្រៅប្រទេស ប្រសិនបើមានការឧបត្ថម្ភពីភាគីជាដៃគូ ប្រគល់សិទ្ធិជូនឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកដើម្បីពិនិត្យ សម្រេច (ចាប់ពីមន្ត្រីធម្មតារហូតដល់អគ្គនាយករង)។ ចំពោះប្រធានអង្គភាពអាចចរន្តបន្តទៅរដ្ឋមន្ត្រី។ ក្នុងករណីប្រើប្រាស់ថវិកាជាតិ ត្រូវចរន្តបន្តទៅរដ្ឋមន្ត្រីដើម្បីសម្រេច

- យកចិត្តទុកដាក់ផ្សព្វផ្សាយនៅក្នុងទំព័រសារព័ត៌មាន Website Facebook ក្រសួងអំពីសកម្មភាពការងាររបស់ថ្នាក់ដឹកនាំមិនមែនមានតែរដ្ឋមន្ត្រីម្នាក់ឯង ក៏ដូចជានៅតាមអង្គភាពជំនាញនីមួយៗផងដែរ។ ថ្នាក់ដឹកនាំទទួលបន្ទុកអាចធ្វើសន្និសីទសារព័ត៌មានតាមការចាំបាច់ ចំពោះព្រឹត្តិការណ៍ ឬបញ្ហាប្រឈមទាំងឡាយដែលត្រូវចូលរួម និងដោះស្រាយបន្ទាន់

- ថ្នាក់ដឹកនាំក្រសួងមិនត្រូវយកតួនាទីរបស់ខ្លួនធ្វើជាខ្នងបង្អែកឲ្យឈ្មួញ ឬក្រុមបក្សពួករបស់ខ្លួនឡើយ

- ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតទៅលើបញ្ហាប្រឈមរបស់ប្រជាកសិករ និងប្រជាពលរដ្ឋទូទៅ

- ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការត្រូវប្រកាន់ខ្ជាប់នូវសាមគ្គីផ្ទៃក្នុងខ្ពស់ក្នុងការបំពេញភារកិច្ច ដោយត្រូវចេះសហការគ្នាក្នុងការបំពេញតួនាទី និងភារកិច្ចជូនក្រសួង

- ថ្នាក់ដឹកនាំទទួលបន្ទុកអង្គភាពជំនាញនីមួយៗ ត្រូវយកចិត្តទុកដាក់អនុវត្តភារកិច្ចក្នុងស្មារតីទទួលខុសត្រូវទៅតាមឋានានុក្រម ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពនីមួយៗ ឲ្យមានភាពរលូន មានប្រសិទ្ធភាព និងទាន់ពេលវេលា

- ត្រូវពិនិត្យ និងផ្តល់គ្រឿងឥស្សរិយយសចំពោះមន្ត្រីដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជូនជាតិ ម្យ៉ាងវិញទៀតត្រូវដំឡើងកាំប្រាក់ជូនដល់មន្ត្រីក្រោមឱវាទឲ្យបានទៀងទាត់ និងសុក្រិតភាព

- ត្រូវរៀបចំថវិកា និងមន្ត្រីឲ្យបានគ្រប់គ្រាន់ សម្រាប់ធ្វើអន្តរាគមន៍ចាំបាច់ក្នុងការឆ្លើយតបទៅតាមភាពចាំបាច់ក្នុងការជួយដល់កសិករ ដែលប្រឈមទៅនឹងគ្រោះមហន្តរាយដោយយថាហេតុនាពេលខាងមុខ

- អគ្គនាយកដ្ឋាននិងនាយកដ្ឋានជំនាញត្រូវខិតខំស្វែងរកទីផ្សារជូនប្រជាពលរដ្ឋ ដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការផលិតដំណាំកសិកម្ម កសិ-ឧស្សាហកម្ម ការធ្វើវារីវប្បកម្ម និងការចិញ្ចឹមសត្វក្នុងស្រុក

- អគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវតាមដានជាប្រចាំលើគុណភាពសម្ភារកសិកម្មជាពិសេសគុណភាពជី ថ្នាំសម្លាប់សត្វល្អិត ពូជ ។ល។

- គ្រប់អង្គភាពទាំងអស់ ត្រូវចាត់ចែងឆ្លើយតបរាល់គ្រប់លិខិតបទដ្ឋានទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យបានទាន់ពេលវេលា។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ឯកឧត្តម លោក លោកស្រី គ្រប់អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកចិត្តទុកដាក់កែលម្អ អនុវត្តឲ្យទទួលបានលទ្ធផលជាវិជ្ជមានក្នុងស្មារតីទទួលខុសត្រូវ។

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន